# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ៖ សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ **បារាំង/ ប្រែសម្រួលជាភាសាខ្មែរ**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 30-May-2013, 14:26
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយសហចៅក្រមស៊ើបអង្កេត ឬដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

## សំណើសុំដាក់ឯកសារភ័ស្តុតាងបន្ថែម ជូនអង្គជំនុំជម្រះសាលាដំបូង ដោយអនុលោមតាមវិធាន ៨៧.៤ នៃវិធានផ្ទៃក្នុង

---

ដាក់ដោយ៖

**សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី**

មេធាវី ពេជ អង្គ

មេធាវី Elisabeth SIMONNEAU-FORT

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី

ហុង គឹមសួន

ដាក់ជូន៖

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន ប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យូរ ឧត្តរា

គីម ម៉េងឃី
គង់ ផល្លា
ឡោ ជុនធី
ម៉ុច សុវណ្ណារី
ស៊ិន សុវ៉ន
សំ សុគង់
ទី ស្រីនណា
វ៉ែន ពៅ
Emmanuel ALTIT
Pascal AUBOIN
Olivier BAHOUGNE
Patrick BAUDOIN
Evelyne BOILEAU-BRANDOMIR
Philippe CANONNE
Annie DELAHAIE
Laure DESFORGES
Ferdinand DJAMMEN NZEPA
Elodie DULAC
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Marie GUIRAUD
Emmanuel JACOMY
Martine JACQUIN
Daniel LOSQ
Christine MARTINEAU
Mahdev MOHAN
Barnabé NEKUIE
Lyma NGUYEN
Elisabeth RABESANDRATANA
Julien RIVET
Fabienne TRUSSES NAPROUS
Nushin SARKARATI
Philippine SUTZ
Jean SULZER
Beini YE

**ចម្លងជូន៖**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

លោក យ៉េត ចរិយា

លោក William SMITH

**ជនជាប់ចោទ៖**

ខៀវ សំផន

នួន ជា

**សហមេធាវីការពារក្តី៖**

មេធាវី ស៊ុន អារុណ

មេធាវី Victor KOPPE

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

មេធាវី Arthur VERCKEN

មេធាវី Jacques VERGES

## ១. សេចក្តីផ្តើម

១. ផ្អែកលើវិធាន ៨៧.៤ នៃវិធានផ្ទៃក្នុង ដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំការអនុញ្ញាតិពីសំណាក់អង្គជំនុំជម្រះសាលាដំបូងដើម្បីដាក់បញ្ចូលទៅក្នុងកិច្ចពិភាក្សាដេញដោល នូវឯកសារថតសម្លេងបទសម្ភាសជាមួយលោក ខៀវ សំផន ពីសំណាក់លោក Laure DE VULPIAN ដែលចាក់ផ្សាយតាមវិទ្យុ France Culture កាលពីថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០០៧។

២. ដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ភ្ជាប់ទៅនឹងសំណើសុំនេះ នូវថាសសម្លេងថតចម្លងបទសម្ភាសខាងលើនេះ ព្រមទាំងឯកសារប្រតិចារិកកិច្ចសម្ភាសនោះឡើងវិញជាភាសាបារាំង ដែលរៀបចំដោយដើមបណ្តឹងរដ្ឋប្បវេណី។

៣. ដើម្បីជួយសម្រួលឲ្យកិច្ចដំណើរការនីតិវិធីប្រព្រឹត្តទៅបានឆាប់រហ័ស ដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញតែផ្នែកមួយនៃកម្មវិធីផ្សាយរបស់វិទ្យុប៉ុណ្ណោះ ពោលគឺកម្មវិធីដែលពាក់ព័ន្ធនឹងបទសម្ភាសជាមួយលោក ខៀវ សំផន ពីសំណាក់អ្នកសារព័ត៌មានមួយរូបគឺលោក Laure DE VULPIAN។

៤. ឯកសារនេះគឺជាឯកសារមួយដែលមានសារៈសំខាន់បំផុត ដោយហេតុថា ព័ត៌មាននៅក្នុងនោះបានមកពីលោក ខៀវ សំផន ដោយផ្ទាល់។

៥. ឯកសារខ្សែរអាត់បទសម្ភាសនេះ មានសារៈសំខាន់ចាំបាច់ដល់ការបង្ហាញការពិត ហើយការដាក់បញ្ចូលឯកសារនេះទៅក្នុងសំណុំរឿងនឹងបានជាប្រយោជន៍ដល់យុត្តិធម៌។

## ២. អំពីច្បាប់ដែលត្រូវអនុវត្ត

៦. វិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ បានផ្តល់នូវអំណាចឆន្ទានុសិទ្ធិទូលំទូលាយដល់អង្គជំនុំជម្រះសាលាដំបូង ក្នុងការសម្រេចទទួលយកឯកសារនេះទុកដូចជាឯកសារភ័ស្តុតាងក្នុងសំណុំរឿង[1] ដរាបណាឯកសារទាំងនេះ ដោយគ្រាន់តែបានពិនិត្យភ្លាម (*prima facie*) ត្រូវបានសង្កេតឃើញ

---

[1] វិធាន ៨៧ (១) នៃវិធានផ្ទៃក្នុង វិសោធនកម្មលើកទី ៨ ចែងថា៖ “លើកលែងតែមានបទប្បញ្ញត្តិផ្សេងក្នុងវិធានផ្ទៃក្នុងនេះ រាល់ភស្តុតាងទាំងអស់ត្រូវតែទទួលយក។ សហព្រះរាជអាជ្ញាមានបន្ទុកបញ្ជាក់ពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ ដើម្បីផ្តន្ទាទោសជនជាប់ចោទ អង្គជំនុំជម្រះសាលាដំបូងត្រូវមានជំនឿដោយគ្មានវិមតិសង្ស័យអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។”

ថា មានលក្ខណៈសមស្រប គួរឲ្យជឿជាក់បាន និងស្របច្បាប់ ដូចដែលបានកំណត់ដោយវិធាន ៨៧.៣ នៃវិធានផ្ទៃក្នុង[2]។

៧. វិធាន ៨៧.៤ នៃវិធានផ្ទៃក្នុងបានចែងថា "ក្នុងកំឡុងពេលសវនាការ តាមគំនិតផ្តួចផ្តើមរបស់អង្គជំនុំជម្រះ ឬ តាមការស្នើសុំរបស់ភាគី អង្គជំនុំជម្រះអាចកោះហៅ ឬស្តាប់ចម្លើយបុគ្គលណាម្នាក់ក្នុងឋានៈជាសាក្សី ឬទទួលយកនូវភស្តុតាងថ្មី ដែលមានប្រយោជន៏សម្រាប់នាំមកនូវការស្វែងរកការពិត។ គ្រប់ភាគីដែលបានស្នើសុំត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំនេះឲ្យបានច្បាស់លាស់ ។ អង្គជំនុំជម្រះនឹងធ្វើសេចក្តីសម្រេចចំពោះការស្នើសុំនោះ ផ្អែកតាមខ្លឹមសារដែលមានចែងនៅក្នុងវិធាន ៨៧(៣) ខាងលើ ។ ភាគីដែលស្នើសុំត្រូវតែធ្វើឲ្យអង្គជំនុំជម្រះជឿជាក់ថាសក្ខីកម្ម ឬភស្តុតាងដែលបានស្នើសុំនោះ ពុំអាចរកបាននៅមុនពេលការចាប់ផ្តើមជំនុំជម្រះ។"

៨. ម្យ៉ាងទៀត នៅក្នុងសេចក្តីសម្រេចដែលពាក់ព័ន្ធនឹងឯកសារថ្មីនេះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា៖ "ពាក់ព័ន្ធនឹងរាល់ឯកសារទាំងឡាយដែលពុំមាននៅក្នុងបញ្ជីឯកសារដែលបានដាក់ដោយភាគីស្របទៅនឹងដីការបស់អង្គជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ភាគីមានលទ្ធភាពដូចគ្នាក្នុងការដាក់នូវសំណើសុំបង្ហាញឯកសារភ័ស្តុតាងថ្មីនាពេលក្រោយ ស្របតាមវិធាន ៨៧.៤ នៃវិធានផ្ទៃក្នុង ប្រសិនណាជាភាគីយល់ឃើញថា ឯកសារទាំងនោះមានប្រយោជន៍ដល់ការស្វែងរកយុត្តិធម៌។"[3]។

---

[2] វិធាន ៨៧ (៣) នៃវិធានផ្ទៃក្នុង វិសោធនកម្មលើកទី ៨ ចែងថា៖ "អង្គជំនុំជម្រះសាលាដំបូងធ្វើសេចក្តីសម្រេចដោយផ្អែកលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង ប្រសិនបើភាគីយកភស្តុតាងទាំងនោះមកដាក់នៅចំពោះមុខអង្គជំនុំជម្រះ ឬប្រសិនបើអង្គជំនុំជម្រះខ្លួនឯងយកភស្តុតាងទាំងនោះមកដាក់នៅចំពោះមុខភាគី។ ភស្តុតាងដែលមាននៅក្នុងសំណុំរឿង ត្រូវបានចាត់ទុកថាបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះ ឬភាគី បើសិនជាខ្លឹមសាររបស់វាត្រូវបានសង្ខេប ត្រូវបានអាន ឬត្រូវបានកំណត់បង្ហាញអត្តសញ្ញាណយ៉ាងសមស្របក្នុងសវនាការ។ អង្គជំនុំជម្រះសាលាដំបូងអាចបដិសេធចំពោះពាក្យសុំឲ្យពិនិត្យភស្តុតាង បើយល់ឃើញថា៖

ក- មិនជាប់ពាក់ព័ន្ធ ឬជាការស្នើសុំជាន់គ្នា

ខ- មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ

គ- មិនសមស្របសំរាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង

ឃ- ច្បាប់មិនអនុញ្ញាត ឬ

ង- មានចេតនាពន្យារកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៏។"

[3] សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២ ឯកសារ **E190**

## ៣. អំពីភាពដែលអាចទទួលយកបាននៃសំណើសុំ

៩. ឯកសារដែលបានដាក់ជូនអង្គជំនុំជម្រះសាលាដំបូង គឺជាឯកសារថតសម្លេងបទសម្ភាសជាមួយលោក ខៀវ សំផន ដែលចាក់ផ្សាយតាមវិទ្យុបារាំង France Culture កាលពីថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០០៧ ក្នុងកម្មវិធីមួយដែលមានឈ្មោះថា "កម្ពុជា ដែនដីនៃសត្វខ្លាដែលបាត់ខ្លួន"។ វិទ្យុ France Culture គឺជាវិទ្យុផ្សាយសម្លេងវប្បធម៌នៃគ្រឹស្ថានសេវាសាធារណៈផ្នែកសោតទស្សន៍បារាំង ដែលបង្កើតចេញអំពីក្រុមវិទ្យុបារាំង។ France Culture ជាស្ថានីយ៍វិទ្យុដែលមានលក្ខណៈឯករាជ្យ មិនបម្រើនយោបាយ និងគ្មានចំណងពាក់ព័ន្ធជាមួយនឹងភាគីណាមួយនៃរឿងក្តីបច្ចុប្បន្នឡើយ។ បទសម្ភាសនោះធ្វើឡើងដោយផ្ទាល់ ដោយអ្នកកាសែតបារាំងឈ្មោះលោក Laure DE VULPIAN ជាមួយលោក ខៀវ សំផន។ ការចាក់ផ្សាយនៃកិច្ចសម្ភាសនេះគឺធ្វើឡើងជាសាធារណៈ ហើយសាធារណជនអាចស្វែងរកឯកសារផ្សាយសម្លេងនេះបាននៅលើគេហទំព័រនៃវិទ្យុនោះ។ វាច្បាស់ណាស់ថា ឯកសារនេះ គ្រាន់តែពិនិត្យភ្លាម (*prima facie*) ឃើញថា បានបំពេញលក្ខខណ្ឌនៃភាពដែលអាចជឿជាក់បាន និងស្របច្បាប់ ដូចដែលបានលើកឡើងដោយវិធាន ៨៧.៣ នៃវិធានផ្ទៃក្នុង។ ចរិតលក្ខណៈសមហេតុផលនៃឯកសារនេះត្រូវបានបញ្ជាក់លម្អិតនៅក្នុងចំណុច ១២ និងបន្តបន្ទាប់ទៀតខាងក្រោម។

១០. ទោះបីជាឯកសារនេះអាចត្រូវបានគេដឹងជាសាធារណៈ មុនពេលដែលមានការដាក់បញ្ជើដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយ ជាក់ស្តែង ដើមបណ្តឹងរដ្ឋប្បវេណីទើបតែស្វែងរកឃើញ និងទទួលបានឯកសារនេះក្នុងពេលថ្មីៗនេះតែប៉ុណ្ណោះ ពោលគឺបន្ទាប់ពីពេលដែលខ្លួនបានធ្វើការស្រាវជ្រាវស៊ីជម្រៅនោះ។ នៅគ្រប់ករណីទាំងអស់ និងបើផ្អែកលើយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះ[4] ដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថា ឯកសារភ័ស្តុតាងថ្មីនេះអាចទទួលយកបានពីសំណាក់អង្គជំនុំជម្រះ ដោយហេតុថា ឯកសារនេះបានបង្ហាញអំពីចំណងពាក់ព័ន្ធជិតស្និទ្ធទៅនឹងឯកសារភ័ស្តុតាងនានាដែលបានដាក់បញ្ចូលទៅក្នុងសំណុំរឿងរួចហើយ ស្តីអំពីតួនាទីរបស់លោក ខៀវ សំផន ក្នុងរបប

---

កថាខណ្ឌ ២១ និងត្រូវបានលើកឡើងម្តងទៀតនៅក្នុងចម្លើយតបរបស់អង្គជំនុំជម្រះទៅនឹងសំណើតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងរបស់សហព្រះរាជអាជ្ញា ជនជាប់ចោទ នួន ជា និង ខៀវ សំផន ឯកសារ **E276/2** កថាខណ្ឌ ៣។

[4] ដូចយោងខាងលើ។

ខ្មែរក្រហម ដែលឯកសារនេះមានសារៈសំខាន់ដល់ការបង្ហាញការពិត និងឆ្លើយតបទៅនឹងអត្ថប្រយោជន៍នៃយុត្តិធម៌។

១១. នៅក្នុងបទសម្ភាសនេះ លោក ខៀវ សំផន បានផ្តល់នូវព័ត៌មានសមហេតុសមផល ច្បាស់លាស់ពាក់ព័ន្ធនិងសំណុំរឿងបច្ចុប្បន្ន ជាពិសេសពាក់ព័ន្ធការគាំទ្រ និងចូលរួមទៅក្នុងនយោបាយដឹកនាំប្រទេសរបស់ពួកខ្មែរក្រហម។

. អំពីការដឹងឮរបស់គាត់អំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត។

. អំពីឆន្ទៈរបស់គាត់ដែលមិនចង់ប្រឆាំងទៅនឹងនយោបាយរបស់ពួកខ្មែរក្រហម។

. គាត់បានបញ្ជាក់ និងរៀបរាប់ផងដែរអំពីលក្ខខណ្ឌជីវភាពរបស់គាត់នៅក្នុងចំណោមមេដឹកនាំកម្ពុជា។

. គាត់បានបញ្ជាក់ថា គាត់ពុំដែលភ័យខ្លាចចំពោះនយោបាយបោសសម្អាតផ្ទៃក្នុងរបស់បក្សឡើយ ដោយហេតុថា គាត់តែងតែគោរពវិន័យយ៉ាងខ្ជាប់ខ្ជួន។

និងជាចុងបញ្ចប់ គាត់បានបញ្ជាក់ថា គាត់បានដឹងថាមានមនុស្សជាច្រើននៅជុំវិញខ្លួនគាត់បានបាត់ខ្លួនជាបន្តបន្ទាប់។

១២. ជាមួយគ្នានេះ នៅក្នុងអំឡុងនៃបទសម្ភាសដែលបានធ្វើជាមួយវិទ្យុ France Culture កាលពីខែសីហា ឆ្នាំ ២០០៧៖

## *ក. លោក ខៀវ សំផន ក៏បានលើកឡើងផងដែរអំពីការចូលរួមរបស់គាត់ទៅក្នុងនយោបាយរបស់ ប៉ុល ពត និងឆន្ទៈមិនហ៊ានធ្វើការប្រឆាំងទៅនឹង ប៉ុល ពត*

១៣. "រហូតមកទល់នឹងឆ្នាំ ១៩៧៥ ប៉ុល ពត បានសង្កេតឃើញថាខ្ញុំគឺជាជនស្នេហាជាតិមួយរូប ប៉ុន្តែពុំមែនមានតែ ប៉ុល ពត ម្នាក់ដែលមើលឃើញដូច្នេះទេ ប៉ុន្តែ ចលនាតស៊ូទាំងមូលក៏មើលឃើញដូចគ្នាដែរ។ ប៉ុន្តែហេតុដូចម្តេចបានជាក្រោយជ័យជំនះ ពួកគេបានប្រព្រឹត្តនូវរឿងដូចគ្នាទៅវិញ? ការណ៍ដែលបានធ្វើឲ្យជនរួមជាតិកម្ពុជាបាត់បង់អាយុជីវិត ចំណុចនេះ ខ្ញុំសង្កេតឃើញថាវាមានលក្ខណៈផ្ទុយគ្នាទាំងស្រុងទៅនឹងឆន្ទៈស្នេហាជាតិ ខ្ញុំរកយល់ពុំឃើញឡើយ[5] (...) ខ្ញុំបានសួរខ្លួន

[5] "ប្រតិចារឹកបទសម្ភាសន៍របស់ ខៀវ សំផន នៅវិទ្យុ France Culture" ទំព័រ ២ បន្ទាត់ ២០ ដល់ ២៣ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០០៧ (តទៅនេះ ហៅថា "ប្រតិចារឹកបទសម្ភាសន៍")។

ឯងថា តើខ្ញុំត្រូវចាកចេញ? ចាកចេញពី ប៉ុល ពត? (...) តើត្រូវធ្វើការផ្តាច់ខ្លួនយ៉ាងដូចម្តេច? ប៉ុន្តែ ចំពោះរូបខ្ញុំផ្ទាល់ ក្នុងនាមជាបញ្ញវន្ត តើត្រូវធ្វើការផ្តាច់ខ្លួនយ៉ាងដូចម្តេច?[6] (...) ជាសត្យានុម័ត ប្រឆាំងនឹង ប៉ុល ពត បានសេចក្តីថា យើងចូលរួមជាមួយវៀតណាម (...)[7] ។ **ប្រសិនណាជាខ្ញុំប្រឆាំងនឹង ប៉ុល ពត នោះខ្ញុំគឺជាជនក្បត់មួយម្នាក់។ ដូច្នេះ ខ្ញុំមិនអាចធ្វើដូច្នោះបានទេ។ ហើយខ្ញុំក៏មិនចង់ធ្វើដូច្នោះដែរ។ ខ្ញុំមិនអាចទទួលយកស្ថានភាពបែបនោះបានទេ។ ចំពោះសតិអារម្មណ៍របស់ខ្ញុំផ្ទាល់ (...)[8] ពុំមានជម្រើសណាមួយដែលអាចទៅរួចឡើយ។[9]**" ។

### *ខ. លោក ខៀវ សំផន បានអះអាងថា លោកពុំដែលភ័យខ្លាចការបោសសម្អាតផ្ទៃក្នុងរបស់បក្សឡើយ*

១៤. "សំណួរ៖ ចំពោះលោកផ្ទាល់ តើលោកមានដែលធ្លាប់ភ័យខ្លាចថា ថ្ងៃណាមួយនឹងត្រូវបានបក្សបោសសម្អាតដែរទេ?

ចម្លើយ៖ ខ្ញុំមិនដែលមានអារម្មណ៍ភ័យខ្លាចម្តងណាឡើយ ដោយហេតុថា ខ្ញុំផ្ទាល់ គឺខ្ញុំបានគោរពវិន័យរបស់បក្សបានខ្ជាប់ខ្ជួន។ ម្យ៉ាងវិញទៀត រូបខ្ញុំផ្ទាល់ គឺស្ថិតនៅជាប្រចាំជាមួយមេដឹកនាំខ្មែរក្រហម។ ខ្ញុំសូមប្រាប់លោកថា ប៉ុល ពត មានការទុកចិត្តចំពោះខ្ញុំ។[10]" ។

### *គ. លោក ខៀវ សំផន ទទួលស្គាល់ថា មានមនុស្សជាច្រើនដែលនៅជុំវិញគាត់បានបាត់ខ្លួន*

១៥. "សំណួរ៖ តើលោកមានបានដឹងថា មិត្តភក្តិរបស់លោក ឬអ្នកដែលមានឋានៈប្រហាក់ប្រហែលលោក បានបាត់ខ្លួនជាបន្តបន្ទាប់នោះទេ?

---

[6] ដូចយោងខាងលើ ទំព័រ ២ បន្ទាត់ ២៧ ដល់ ២៩។

[7] ដូចយោងខាងលើ ទំព័រ ២ បន្ទាត់ ៣២។

[8] ដូចយោងខាងលើ ទំព័រ ៣ បន្ទាត់ ៣ បន្ទាត់ ២០ ដល់ ២២។

[9] ដូចយោងខាងលើ ទំព័រ ៣ បន្ទាត់ ២៥។

[10] ដូចយោងខាងលើ ទំព័រ ៣ បន្ទាត់ ១ ដល់ ៥។

**ចម្លើយ៖ បាទ ខ្ញុំតែងតែមានសង្ឃឹមថា ប៉ុល ពត នឹងត្រលប់មកយកក្រោយវិញនាថ្ងៃណាមួយជាក់ជាពុំខាន។[11]"**

១៦. ចំណុចដែលដកស្រង់ខាងលើនេះបញ្ជាក់ឲ្យឃើញថា ខៀវ សំផន បានដឹងច្បាស់អំពីការបាត់ខ្លួននោះ គាត់បានដឹង និងបានឃើញ។ ចំណុចនេះមានលក្ខណៈផ្ទុយគ្នាទាំងស្រុងទៅនឹងសក្ខីកម្មជាច្រើនដែលតាមរយៈនោះ លោក ខៀវ សំផន បានអះអាងថាគាត់ពុំបានដឹងរឿងអ្វីទាំងអស់ ជាពិសេសអំពីការបោសសម្អាត និងការបាត់ខ្លួនសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជា[12]។

## ឃ. *ការប្តេជ្ញាចិត្តរបស់ ខៀវ សំផន ក្នុងការមិនធ្វើការសុំទោសជាសាធារណៈ ចំពោះព្រឹត្តិការណ៍ដែលបានកើតមានឡើងក្នុងរបបខ្មែរក្រហម*

---

[11] ដូចយោងខាងលើ ទំព័រ ៣ បន្ទាត់ ១៨ ដល់ ២០។

[12] *"ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់"* និពន្ធដោយ ខៀវ សំផន ឯកសារ **IS4.23**, ERN ជាភាសាបារាំង 00595492-00595493, ERN ជាភាសាខ្មែរ 00103879 "ទោះបីជាយ៉ាងណាក៏ដោយ បើពិនិត្យដោយយុត្តិធម៌ទៅ គេពុំអាចចាត់ទុកការដែលខ្ញុំបានប្រកាន់គោលជំហរជាបន្តបន្ទាប់ ដូចខ្ញុំបានជម្រាបខាងលើថាជាអំពើឃុបឃិតសមគំនិតជាមួយអំពើកាប់សម្លាប់នោះទេ។ ដូចខ្ញុំបានជម្រាបក្នុងសំបុត្រចំហររបស់ខ្ញុំចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០១ រួចមកហើយ ខ្ញុំពុំបានដឹងអំពីទំហំនៃអំពើកាប់សម្លាប់ថាវាអាចធំធេងដល់ប៉ុណ្ណឹងសោះឡើយ នៅពេលដែលអំពើប្រព្រឹត្តិទាំងអស់នោះបានកើតឡើង។", លិខិតចំហទីពីររបស់ ខៀវ សំផន ឯកសារ **E3/592**, ERN ជាភាសាបារាំង 00623777, ERN ជាភាសាខ្មែរ 00002800 ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៣៖ "ប៉ុន្តែ ខ្ញុំសុំសារភាពថាខ្ញុំទើបតែឃើញលក្ខណៈជាខ្សែសង្វាក់នៃការរាតត្បាតចាប់ចងនៅពេលថ្មីៗនេះទេ ហើយខ្ញុំនិយាយឲ្យច្បាស់តែម្តងទៅ គឺនៅពេលដែលខ្ញុំមើលខ្សែភាពយន្តរបស់លោក រិទ្ធី ប៉ាន់ ដែលមានចំណងជើងថា "ស២១ កន្លែងខ្មែរក្រហមសម្លាប់មនុស្ស"។ នៅឆ្នាំ១៩៧៥-៧៨ ខ្ញុំមិនដែលស្គាល់ ហើយក៏មិនដែលឮនិយាយពី "ស២១" ទាល់តែសោះទេ។", ខ្សែភាពយន្តមានចំណងជើងថា៖ «*Cambodia, Facing Genocide*» របស់ David Aronowitsch និង Staffan Lindberg ឯកសារ **E109/2.3**, V00720415 នាទីទី ៥៤ និង ២៨ វិនាទី "-២១ ខ្ញុំមិនដឹងទេ! ខ្ញុំមិនដឹងអ្វីសោះ!", ខ្សែភាពយន្តមានចំណងជើងថា៖ « *Survive in the Heart of the Khmer Rouge Madness* » របស់ Roshane Saidnattar ឯកសារ **E109/2.3**, V00720414 នាទីទី ២៩ និង ០៩ វិនាទី "ប៉ុន្តែ ទាក់ទិននឹងការសម្លាប់រង្គាលប្រជាជន ខ្ញុំមិនបានដឹងទេ។ ខ្ញុំមិនបានឃើញអ្វីសោះ... ខ្ញុំមិនបានចាប់អារម្មណ៍ទេ។", កំណត់ហេតុនៃការសួរចម្លើយដោយការិយាល័យសហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៧ ឯកសារ **E3/210**, ERN ជាភាសាបារាំង 00156695, ERN ជាភាសាខ្មែរ 00156690៖ "សំណួរ៖ តើលោកថាលោកមិនមានបានដឹងអំពីការចាប់ខ្លួនណាមួយសោះមុនឆ្នាំ ១៩៧៩ មែនទេ? - ឆ្លើយ៖ មិនមែនមិនដឹងសោះនោះទេ។ ខ្ញុំបានឃើញសមាជិកមួយចំនួនរបស់គណៈកម្មាធិការមជ្ឈិម បាត់ខ្លួនម្តងមួយៗ។ ខ្ញុំមិនអាចផ្តល់ជូនលោកចៅក្រមអំពីឈ្មោះពួកគេបានទេ ពីព្រោះខ្ញុំមិនជិតស្និទ្ធិនឹងពួកគេនោះទេ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំមិនដឹងទាល់តែសោះអំពីទំហំនៃហេតុការណ៍នោះ។"។

សំណើសុំដាក់ឯកសារភ័ស្តុតាងបន្ថែមជូនអង្គជំនុំជម្រះ
សាលាដំបូងដោយអនុលោមតាមវិធាន ៨៧.៤ នៃវិធានផ្ទៃក្នុង

១៧. “ សំណួរ៖ តើលោកមានបំណងចង់ធ្វើការសុំអភ័យទោស សុំនូវការលើកលែងទោសអំពីប្រជាជនកម្ពុជា ចំពោះហេតុការណ៍ដែលបានកើតមានឡើងពីអតីតកាលដែរឬទេ? តើចំពោះលោកខ្លួនឯងផ្ទាល់ តើលោកមានអារម្មណ៍សោកស្តាយចំពោះហេតុការណ៍ទាំងនោះដែរឬទេ?
ចម្លើយ៖ ធ្វើការសុំទោស សំដែងការសោកស្តាយ អត់ទេ ខ្ញុំមិនអាចធ្វើបានទេ ពីព្រោះថាទង្វើអស់ទាំងនេះនឹងបង្កើតជាការយល់ច្រលំទៅលើរឿងនេះ [13]”។

១៨. ឯកសារភ័ស្តុតាងមួយនេះពិតជាមានសារសំខាន់ខ្លាំងដល់ការបង្ហាញការពិត និងដល់ដើមបណ្តឹងរដ្ឋប្បវេណី។ ជាក់ស្តែង ចាប់តាំងពីថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ លោក ខៀវ សំផន បានបដិសេធមិនធ្វើការបកស្រាយអ្វីទាំងអស់ ដោយលោកមានបំណងកាត់ផ្តាច់ យុត្តិធម៌ និងដើមបណ្តឹងរដ្ឋប្បវេណីអំពីព័ត៌មានទាំងឡាយដែលមានសារសំខាន់ដល់ការបង្ហាញការពិត ប្រសិនណាជាខ្វះនូវព័ត៌មានទាំងនោះ ការកសាងនូវធនធានមនុស្ស និងសង្គមជាតិទាំងមូលពិតជាពុំអាចធ្វើទៅបានពេញលេញឡើយ។ បច្ចុប្បន្ននេះទៀតសោត ការណ៍ដែលពុំបានសំដែងនូវការសោកស្តាយចំពោះភាពឈឺចាប់ខ្លោចផ្សាដែលជនរងគ្រោះបានទទួលរង លោក ខៀវ សំផន បានទទួលស្គាល់អំពីជំហររបស់គាត់ក្នុងការគាំទ្រមាគ៌ានយោបាយរបស់ពួកខ្មែរក្រហម។

១៩. ហេតុដូច្នេះ ឯកសារភ័ស្តុតាងនេះបានបង្ហាញនូវលក្ខណសម្បត្តិរបស់ខ្លួនមួយ ដែលប្រយោជន៍នៃយុត្តិធម៌តម្រូវឱ្យដាក់បញ្ចូលឯកសារនេះទៅក្នុងសំណុំរឿង។

## ៤. សំណើសុំ

២០. ដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើដល់អង្គជំនុំជម្រះសាលាដំបូង មេត្តា៖

ក. ទទួលយកឯកសារថ្មីនេះ ដោយអនុលោមតាមវិធាន ៨៧.៤ នៃវិធានផ្ទៃក្នុង។

ខ. ទទួលស្គាល់ថា ឯកសារថ្មីនេះមានសារសំខាន់ដល់ការបង្ហាញការពិត និងដល់ប្រយោជន៍នៃយុត្តិធម៌។

គ. ដាក់បញ្ចូលឯកសារនេះទៅក្នុងសំណុំរឿង។

---

[13] ប្រតិចារឹកបទសម្ភាសន៍ ទំព័រ ៤ បន្ទាត់ ៤៥ ដល់ ៤៦ ទំព័រ ៥ បន្ទាត់ ១ ដល់ ២។

| | | | |
|---|---|---|---|
| ៣០ ឧសភា ២០១៣ | មេធាវី ពេជ អង្គ<br>សហមេធាវីនាំមុខ<br><br>មេធាវី Elisabeth SIMONNEAU-FORT<br>សហមេធាវីនាំមុខ | ទីក្រុងភ្នំពេញ<br><br>ទីក្រុងភ្នំពេញ | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |